ពហុប្រភពជាតិសំណះ

តើមានជាតិសំណនៅក្នុងផ្ទះ ឬនៅជុំវិញផ្ទះរបស់អ្នកឬដែរទេ?

អ្នកមិនអាចមើលឃើញជាតិសំណបានទេ ប៉ុន្តែជាតិសំណអាចមាននៅគ្រប់ទីកន្លែងនៅក្នុងផ្ទះ និងក្រៅផ្ទះរបស់អ្នក។ ជាតិសំណគឺមានគ្រោះថ្នាក់ ហើយអាចបង្កការគ្រោះថ្នាក់ដល់សុខភាព ជាពិសេសចំពោះកុមារ។ ការពុលជាតិសំណកើតឡើងនៅពេលដែលជាតិសំណត្រូវបានលេបចូលទៅក្នុងពោះ ឬត្រូវបានស្រូបចូលតាមផ្លូវដង្ហើម។ កុមារជាច្រើនដែលមានជាតិសំណពុលក្នុងខ្លួនមិនមានបង្ហាញរោគសញ្ញា ឬអាការៈឈឺណាមួយទេ។

ជាតិសំណអាចត្រូវបានគេរកឃើញនៅៈ



ក្នុងថ្នាំលាបចាស់ៗដែលមានរបករលាត់ចេញ



ក្នុងគ្រឿងសំអាងបែបប្រពៃណីមានដូចជា ខោល (kohl) សួរ៉ាម៉ា (surma) ឬ សិនដូរ (sindoor)

ក្នុងធូលីផ្ទះ

នៅក្នុងថ្នាំបុរាណមួយចំនួន មានដូចជា អាហ្សាកន (azarcon) ក្រេតា (greta) ឬ ផេឡូអា (pay-loo-ah)

ក្នុងវាលដីកខ្វក់

ក្នុងគ្រាប់កាំភ្លើង និងកូនសណ្តូននេសាទត្រី



ក្នុងអាហារ សុរគ្រាប់ និងគ្រឿងទេសមួយចំនួនដែលនាំចូលមកពីខាងក្រៅសហរដ្ឋអាមេរិក

ក្នុងចាន និងឆ្នាំងមួយចំនួន

លើសក់ស្បែកស្បែកជើង និងសម្លៀកបំពាក់របស់អ្នក ប្រសិនបើអ្នកធ្វើការពាក់ព័ន្ធជាមួយនឹងជាតិសំណ

ក្នុងខ្យល់ពុលនៅជុំវិញអាកាសយានដ្ឋាន និងតំបន់ឧស្សាហកម្ម



ក្នុងប្រដាប់ក្មេងលេង និងគ្រឿងអលង្ការមួយចំនួន

សូមឱ្យកូនរបស់អ្នកស្ថិតនៅឱ្យឆ្ងាយពីវត្ថុទាំងអស់នេះ និងសូមប្រឹក្សាយោបល់ជាមួយនឹងវេជ្ជបណ្ឌិតរបស់ពួកគេអំពីការធ្វើតេស្តឈាមរកជាតិសំណ។ វិធីតែមួយគត់ដើម្បីដឹងថាកូនរបស់អ្នកមានជាតិសំណពុលឬអត់ គឺត្រូវឱ្យកូនរបស់អ្នកធ្វើតេស្តឈាមរកជាតិសំណ។ កុមារភាគច្រើនត្រូវបានធ្វើតេស្តឈាមរកជាតិសំណនៅអាយុ 1 ឆ្នាំ និង 2 ឆ្នាំ ហើយកុមារមួយចំនួនទៀតដែលមានអាយុលើសពី 2 ឆ្នាំក៏ត្រូវធ្វើតេស្តឈាមរកជាតិសំណដែរ។

CDPH
California Department of Public Health

go.cdph.ca.gov/LeadFreeKids

ខែសីហា ឆ្នាំ 2024 • © 2024 ក្រសួងសុខាភិបាលសាធារណៈរដ្ឋកាលីហ្វ័រញ៉ា

សម្រាប់ការប្រើប្រាស់របស់ភ្នាក់ងារៈ
សូមដាក់ព័ត៌មានទំនាក់ទំនងនៅទីនេះ